## គ) បញ្ហាដែលកើតឡើងជាញឹកញាប់ទាក់ទងទៅនឹងផ្នែកផ្សេងៗនៃច្បាប់:

ដើម្បីជៀសវាងនូវកំហុសធ្ងន់ធ្ងរ អ្នកធ្វើច្បាប់គ្រប់រូបដែលពង្រាងច្បាប់ ព្រមទាំងអ្នកពិនិត្យពង្រាងច្បាប់ គួរចាំក្នុងចិត្តជានិច្ចថា គ្រប់ផ្នែករបស់ច្បាប់ត្រូវតែសមស្របទៅនឹង**សិទ្ធិមនុស្ស** និងគោលការណ៍នៃ**ការបែងចែកអំណាច** ។ ដោយសារគោលការណ៍ទាំងនេះ មានតំរូវការអតិបរមាចំនួនបួន ដែលច្បាប់ត្រូវតែ:

- យុត្តិធម៌
- ទូទៅ
- អរូបី និង
- ច្បាស់លាស់ ។

ជាទីបញ្ចប់ មានតំរូវការផ្លូវការ និងតក្កៈមួយចំនួន ដែលធ្វើឱ្យប្រាកដថា ច្បាប់អាចគ្រប់គ្រង និងបំពេញមុខងាររបស់ខ្លួនក្នុងការដោះស្រាយទំនាស់ បានយ៉ាងពិតប្រាកដ:

ច្បាប់មួយត្រូវតែ:

- ស៊ីសង្វាក់គ្នា
- គ្មានភាពផ្ទុយគ្នា និង
- សមស្របជាមួយច្បាប់ផ្សេងទៀត ។

បញ្ហា និងកំហុសទាំងឡាយដែលអាចធ្វើឱ្យខូចដល់ពង្រាងច្បាប់ណាមួយនោះ តាមធម្មតា កើតចេញពីការមិនគោរពគោលការណ៍ទាំងនេះ ។ ចំពោះហេតុផលនេះ អ្នកពិនិត្យពង្រាងច្បាប់ដ៏សំខាន់ម្នាក់គួរតែជានិច្ចកាលផ្តោតអារម្មណ៍ទៅលើសំនួរថា តើពង្រាងច្បាប់នេះរំលោភលើគោលការណ៍ណាមួយនៃគោលការណ៍ទាំងនេះឬទេ ។

ដោយអាននូវផ្នែកសំខាន់ៗទាំងបួនរបស់ច្បាប់មួយ គេនឹងរកឃើញបញ្ហាចម្បងៗទាំងឡាយខាងក្រោមចំពោះគោលការណ៍ទាំងនេះ:

### I) គោលបំណង និងនិយមន័យ:

#### ១) គោលបំណងមិនស្របតាមរដ្ឋធម្មនុញ្ញ:

អ្នកធ្វើច្បាប់មិនអាចធ្វើតាមគោលបំណងណាមួយ ក្រៅពីគោលបំណងដើម្បីការពារសិទ្ធិមនុស្សរបស់បុគ្គលគ្រប់រូប ដែលពាក់ព័ន្ធនឹងទំនាស់ ដែលច្បាប់ត្រូវដោះស្រាយ ។ ដូច្នេះ នៅក្នុងដំណាក់កាលដំបូងនៃច្បាប់នេះ អ្នកធ្វើច្បាប់ត្រូវតែពិនិត្យមើលថា តើគោលបំណងនៃច្បាប់ (ដូចមានចែងភាគច្រើននៅក្នុងមាត្រា១ នៃច្បាប់) សមស្របជាមួយទស្សនៈសិទ្ធិមនុស្សដែរឬទេ ។

<u>ឧទាហរណ៍:</u>

ច្បាប់មួយដែលមានបំណងលុបបំបាត់សហជីពកម្មករ ឬក៏ដាក់ភារកិច្ចលើសមាគមទាំងអស់ក្នុងការចុះឈ្មោះនោះ មិនសមស្របជាមួយមាត្រាស្តីពីសិទ្ធិមនុស្សដែលពាក់ព័ន្ធនឹងសេរីភាពក្នុងការបង្កើតសមាគមឡើយ ។ ការបង្កើត និងការអនុវត្តន៍សកម្មភាពសហជីពកម្មករ គឺសិទ្ធិជាមូលដ្ឋាន ហើយវាក៏ជាផ្នែកមួយនៃសេរីភាព

ជាមូលដ្ឋានក្នុងការបង្កើតសមាគមផងដែរ ដែលរដ្ឋត្រូវតែផ្តល់ការចុះឈ្មោះជាការផ្តល់ឱកាសទទួលបានឋានៈជានីតិបុគ្គល ប៉ុន្តែមិនមែនដើម្បីប្រើការចុះឈ្មោះបែបបង្ខិតបង្ខំជាមធ្យោបាយមួយនៃការត្រួតពិនិត្យ និងការគ្រប់គ្រងរបស់រដ្ឋឡើយ[២១] ។

### ២) និយមន័យច្បាស់លាស់ និងដែលខ្វះចន្លោះ[២២]

និយមន័យត្រូវតែច្បាស់លាស់ ប្រសិនបើនិយមន័យទាំងនេះធ្វើវិភាគទានចំពោះគោលបំណងច្បាប់ ដើម្បីដោះស្រាយទំនាស់មួយ ។

ប្រសិនបើនិយមន័យទាំងនេះមិនត្រូវបានកំណត់ឱ្យបានច្បាស់ទេនោះ វាពុំអាច ដោះស្រាយទំនាស់បានឡើយ ផ្ទុយទៅវិញ វាបង្កើតបញ្ហាកាន់តែច្រើនជាងមុនថែមទៀត ។ ប្រការនេះ ក៏ជាករណីបំពានសិទ្ធិមនុស្សដែរ ពីព្រោះ ទំនាស់រវាងសិទ្ធិមនុស្សនៃបុគ្គលដែលពាក់ព័ន្ធផ្សេងៗគ្នា មិនត្រូវបានដោះស្រាយ ប៉ុន្តែប្រហែលជាកាន់តែធ្ងន់ធ្ងរថែមទៀតផង ។ លើសពីនេះទៀត ការប្រើពាក្យមិនច្បាស់លាស់អាច បើកទ្វារសំរាប់ការបកស្រាយបែបអត្តនោម័តរបស់រដ្ឋាភិបាល ឬប្រព័ន្ធតុលាការ ដែលអាចរំលោភលើគោលការណ៍នៃការបែងចែកអំណាច ពីព្រោះច្បាប់ត្រូវកំណត់ និងរារាំងអំណាចទាំងពីរនេះ អំពីការដោះស្រាយទំនាស់ ប៉ុន្តែ មិនមែនបណ្តោយឱ្យអំណាចទាំងពីរនេះ ដោះស្រាយទំនាស់ដោយផ្ទាល់ឡើយ ។

ប្រសិនបើនិយមន័យចាំបាច់ មានមិនគ្រប់គ្រាន់នោះ ក៏អាចមានបញ្ហាដូចគ្នានេះដែរ ។

ឧទាហរណ៍ :

- ច្បាប់ចរាចរណ៍ផ្លូវគោកមួយអាចបង្កបញ្ហា ប្រសិនបើច្បាប់នេះមិនពន្យល់ឱ្យបានច្បាស់ថា តើពាក្យថា "អ្នកចូលរួមធ្វើចរាចរណ៍" សំដៅដល់តែអ្នកចូលរួមធ្វើចរាចរដោយរថយន្ត ឬថាតើពាក្យនេះសំដៅដល់អ្នកដំណើរថ្មើរជើងដែរឬយ៉ាងណានោះ? ដូច្នេះ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់អ្នកដំណើរថ្មើរជើង ក៏អាចមិនច្បាស់លាស់ផងដែរ ។ ដូចជា អ្នកបើកបរឡានតូចម្នាក់ អាចទទួលរងការខាតបង់ផ្នែកហិរញ្ញវត្ថុ ប្រសិនបើ គាត់មិនអាចឱ្យអ្នកដំណើរថ្មើរជើង ទទួលខុសត្រូវចំពោះការខូចខាតចំពោះរថយន្តរបស់គាត់ ដែលបង្កឡើងដោយការមិនគោរពច្បាប់ចរាចររបស់អ្នកដំណើរថ្មើរជើងទេនោះ ។
- នៅក្នុងជំពូកទី២ ត្រង់មាត្រា៤ នៃច្បាប់ជលផល ពុំបានផ្តល់និយមន័យឱ្យពិស្តារ និងច្បាស់លាស់ថាតើព្រំដែនណាខ្លះដែលត្រូវរាប់បញ្ចូលទៅក្នុងពាក្យថា "ផ្នែកជលផល"[២៣] នោះឡើយ ។

### ៣) បញ្ហានៃដែនកំណត់របស់ច្បាប់ : សមភាព

សិទ្ធិក្នុងការទទួលបានភាពស្មើគ្នា (មាត្រា៣១ II CC) គឺជាសិទ្ធិមនុស្សមួយក្នុងចំណោម សិទ្ធិមនុស្សដ៏សំខាន់បំផុតជាច្រើនទៀត ។ ដូច្នេះ អ្នកធ្វើច្បាប់ត្រូវប្រាកដថា ច្បាប់ប្រព្រឹត្តិចំពោះមនុស្ស ឬក្រុមមនុស្សដូចៗគ្នា ប្រសិនបើ គ្មានភាពខុសគ្នារវាងពួកគេដែលធ្វើការថ្លឹងថ្លែងលើការប្រព្រឹត្តិផ្សេងមួយទេនោះ ។ ម្យ៉ាងទៀត ចំណុចនេះត្រូវបានធានាដោយការបង្កើតច្បាប់ទូទៅ ដែលត្រូវអនុវត្តចំពោះប្រជាពលរដ្ឋគ្រប់រូប ។ លើសពីនេះ

---

[២១] សូមមើលសៀវភៅរបស់វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ភាគទី១ ស្តីពី "ការពិចារណាពិស្តាផ្នែកគតិយុត្តិ — សិទ្ធិមនុស្ស" ទំព័រទី ៨៣ និងទី ៨៤

[២២] ចំពោះមេរៀនលំអិតស្តីពីរបៀបប្រើនិយមន័យទាំងនេះ សូមមើលបាទ្រីសៀ បារ (Patricia Baars) "ការតាក់តែងច្បាប់" (ខែសីហា ឆ្នាំ ២០០១) ទំព័រទី ៨៣-៩០ ។

[២៣] សូមមើលរបាយការណ៍របស់អង្គការ Oxfam (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០២: "សំយោគមតិយោបល់ដែលទទួលបានតាមរយៈដំណើការពិគ្រោះយោបល់" ទំព័រទី ៣